# ផ្នែកទី ១

## ច្បាប់ស្តីពីជលផល

## ដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ

## ជំពូកទី ១១
## សហគមន៍នេសាទ

**មាត្រា ៥៩.-**

ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានសិទ្ធិរួមគ្នាបង្កើតសហគមន៍នេសាទនៅតាមមូលដ្ឋានរបស់ខ្លួន ដោយឈរលើគោលការណ៍ស្ម័គ្រចិត្ត ដើម្បីចូលរួមគ្រប់គ្រង អភិរក្ស អភិវឌ្ឍ និង ប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាព ។

វិធានដើម្បីបង្កើត និងគ្រប់គ្រងសហគមន៍នេសាទ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៦០.-**

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសិទ្ធិប្រគល់ផ្នែកណាមួយនៃដែននេសាទឱ្យទៅសហគមន៍ដែលរស់នៅក្នុង ឬ ក្បែរដែននេសាទក្រោមរូបភាពជាកន្លែងនេសាទសហគមន៍ ។

**មាត្រា ៦១.-**

ខណ្ឌរដ្ឋបាលជលផល តាមរយៈដំណើរការពិគ្រោះយោបល់ជាមួយសមត្ថកិច្ចពាក់ព័ន្ធដទៃទៀតមានភារកិច្ចសិក្សារៀបចំដែននេសាទដើម្បីបង្កើតជាកន្លែងនេសាទសហគមន៍ ដោយកំណត់ព្រំប្រទល់ច្បាស់លាស់ និងមានទំហំសមស្របផ្អែកតាមលទ្ធភាពធនធានជលផល និងតម្រូវការប្រើប្រាស់ជាប្រពៃណីរបស់សហគមន៍ ។

នាយខណ្ឌរដ្ឋបាលជលផល មានសិទ្ធិសម្រេចចុះ ឬលុបកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ជាមួយសហគមន៍មូលដ្ឋានណាមួយដែលរស់នៅក្នុង ឬ ក្បែរដែននេសាទ។ កិច្ចព្រមព្រៀងនេះ ត្រូវមានសុពលភាពមិនលើសពីរយៈពេលបី ៣) ឆ្នាំ តែអាចពន្យារបាន ដោយផ្អែកលើរបាយការណ៍ពិនិត្យ និងវាយតម្លៃឡើងវិញរបស់ថ្នាក់ផ្នែករដ្ឋបាលជលផល ។

**មាត្រា ៦២.-**

កន្លែងនេសាទសហគមន៍ត្រូវបានគ្រប់គ្រងដោយធានានិរន្តរភាពដោយសហគមន៍នេសាទស្របតាមផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ វិធានសហគមន៍នេសាទ និង គោលការណ៍ណែនាំអំពីសហគមន៍នេសាទ ។ រដ្ឋបាលជលផលត្រូវផ្តល់ជំនួយបច្ចេកទេស តាមការស្នើសុំរបស់សហគមន៍មូលដ្ឋាន និងត្រូវតាមដានត្រួតពិនិត្យការអនុវត្តផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ។

ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ត្រូវរៀបចំដោយសហគមន៍មូលដ្ឋាន និងមានការយល់

ព្រមពីប្រធានរដ្ឋបាលជលផលថ្នាក់កណ្តាល ហើយនិងត្រូវពិនិត្យឡើងវិញ ជារៀងរាល់បី (៣) ឆ្នាំម្តង ឬ មុនពេលកំណត់ក្នុងករណីចាំបាច់ ។

សហគមន៍នេសាទគ្មានសិទ្ធិលក់ ដោះដូរ ជួល ធ្វើអំណោយ ប្រវាស់ បែងចែក ឬ ធ្វើការផ្ទេរកន្លែងនេសាទ សហគមន៍បានឡើយ ។

គោលការណ៍ណែនាំអំពីសហគមន៍នេសាទ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៦៣.-**

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិរំសាយកន្លែងនេសាទសហគមន៍តាមការចាំបាច់ណាមួយសម្រាប់ផលប្រយោជន៍សាធារណៈ ។